# ឧបសម្ព័ន្ធ ឆ (២) ទន្និករណ៍អំពីភាពអាចទទួលយកបានសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ភាពមិនអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ភាពមិនគ្រប់គ្រាន់ នៃឥស្ថានភាពខលខ (ក្រុមមេធាវីជាតិ)

*(សូមមើលឧបសម្ព័ន្ធ ច(១) សម្រាប់គន្លឹះលេខកូដនៃភាពមិនអាចទទួលយកបាន)*

| ឯកសារយោងអង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 12-VSS-00388 | ធី រ៉េត | 3, 7 | ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ចុងឆ្នាំ១៩៧៥ អង្គការបានប្រមូលគាត់ឲ្យចូលកងចល័តកុមារ ដាក់ទារុណកម្មឲ្យធ្វើការជាទម្ងន់ ព្យសនកម្មនេះ ដែលបានប្រព្រឹត្ត តាមផែនការសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគោលនយោបាយនៃការធ្វើប្រតិបត្តិការ មន្ទីរសន្តិសុខ សហករណ៍ ឬការដ្ឋាន។ | ទី ស្រីនណា, វ៉ែន ពៅ |
| 12-VSS-00432 | គ្រី ឡឹង | 5 | ដើមបណ្តឹងរដ្ឋប្បវេណីកើតនៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៥១ ហើយគាត់បានបញ្ជាក់យ៉ាងច្បាស់ថា ប្តីរបស់គាត់ឈ្មោះ ឈឹម ណុល នៅឆ្នាំ ១៩៧៦ ពួកខ្មែរក្រហម បានចាប់យកប្តីរបស់គាត់ទៅ ដាក់ក្នុងមន្ទីរឃុំឃាំង ហើយបានធ្វើទារុណកម្ម និងក្រោយ មកយកប្តីរបស់គាត់ទៅសម្លាប់ចោល ព្យសនកម្មនេះដែលបានប្រព្រឹត្តតាមផែនការសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគោលនយោបាយ នៃការធ្វើប្រតិបត្តិការមន្ទីរសន្តិសុខ សហករណ៍ ឬការដ្ឋាន និងគោលនយោបាយ នៃការអប់រំកែប្រែ សមាសភាពអាក្រក់ និងការសម្លាប់ ខ្មាំង ជាលទ្ធផលគឺស្លាប់ដោយអត់អាហារ និងការបាត់ខ្លួននេះ។ | ទី ស្រីនណា, វ៉ែន ពៅ |

| ឯកសារយោងអង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 12-VSS-00435 | អៀ វឿន | 3 | ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងយ៉ាងច្បាស់ហើយថា ប្តីរបស់គាត់ឈ្មោះ ប៉ែន សុន ជាពេទ្យកងទ័ព នៅអំឡុងដើមឆ្នាំ ១៩៧៦ ត្រូវកម្មាភិបាល ខ្មែរក្រហម យកទៅសម្លាប់ចោលដោយចោទជាជាពួកក្បត់ជាមួយអង្គការ ហើមបងប្រុស និងប្អូនប្រុសរបស់គាត់ក៏ត្រូវបានពួកខ្មែរក្រហមនាំខ្លួនយកទៅបាត់ទៀត នេះតែកាន់បញ្ជាក់ថែមទៀតថា ក្នុងរបបខ្មែរក្រហមទាំងមូលគាត់ពិតជាបាត់បង់នូវសាច់ញាតិ និងមនុស្សជាទីស្រឡាញ់របស់គាត់ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្មារតីរបស់គាត់ និងទទួលរងនូវភាពឈឺចាប់យ៉ាងខ្លាំងរហូតដល់ពេលនេះ។ ការស្លាប់របស់សាច់ញាតិជាទីស្រឡាញ់របស់គាត់ទាំង ៣ នាក់នេះ គឺជាការរងព្យសនកម្មដែលបានប្រព្រឹត្តតាមផែនការសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាគោលនយោបាយ នៃការអប់រំកែប្រែ សមាសភាពអាក្រក់ និងការសម្លាប់ ខ្មាំង ជាលទ្ធផលគឺបានចាប់ខ្លួន អប់រំកែប្រែ កម្ទេច និងបាត់ខ្លួនជាដើម។ | ទី ស្រីនណា, វ៉ែន ពៅ |
| 12-VSS-00440 | សូ យ៉ិន | 5 | ដើមបណ្តឹងបានបញ្ជាក់យ៉ាងច្បាស់ថា នៅឆ្នាំ ១៩៧៦ ប្តីរបស់គាត់ ត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់ចោលដោយចោទថាជាខ្មាំង CIA គិញបង្កប់ ព្យសនកម្មនេះដែលជាលទ្ធផល នៃការកំណត់គោលដៅលើក្រុមជាក់លាក់ គឺការកំណត់គោលដៅលើ ចារកម្ម សេអ៊ីអា/កាហ្សេបេ។ | ទី ស្រីនណា, វ៉ែន ពៅ |

| ឯកសារយោងអង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 12-VSS-00445 | សៅ ណម | 5 | ដើបបណ្តឹងបានបញ្ជាក់ច្បាស់ហើយថា នៅឆ្នាំ ១៩៧៦ ពួកខ្មែរបានមកហៅប្តីរបស់គាត់ថាអោយទៅព្យួស្រែ ក្រោយមកទើបដឹងថាប្តីរបស់គាត់ត្រូវគេយកទៅសម្លាប់ចោល ព្យសនកម្មនេះដែលបានប្រព្រឹត្តតាមផែនការសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគោលនយោបាយ នៃការធ្វើប្រតិបត្តិការមន្ទីរសន្តិសុខ សហករណ៍ ឬការដ្ឋាន និងគោលនយោបាយ នៃការអប់រំកែប្រែ សមាសភាពអាក្រក់ និងការសម្លាប់ ខ្មាំង ជាលទ្ធផលគឺស្លាប់ដោយអត់អាហារ និងការបាត់ខ្លួននេះ។ | ទី ស្រីនណា, វ៉ែន ពៅ |
| 12-VSS-00463 | ប៉ែន អ៊ុន | 7 | ដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា នៅឆ្នាំ១៩៧៦ ឪពុករបស់គាត់ឈ្មោះ អ៊ី ជាអតីតទាហាន លន់ ណុល និងម្តាយឈ្មោះ យ៉ែម ត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់នៅទំនប់កប់ស្រូវជិតទីក្រុងភ្នំពេញ ព្យសនកម្មនេះ ជាលទ្ធផលនៃការកំណត់គោលដៅលើក្រុមជាក់លាក់ គឺការកំណត់គោលដៅ លើអ្នករដ្ឋការសម័យសាធារណរដ្ឋខ្មែរ/លន់ ណុល។ | ទី ស្រីនណា, វ៉ែន ពៅ |

| ឯកសារយោងអង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 12-VSS-00481 | ទុយ វឿន | 3 | ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងយ៉ាងច្បាស់ហើយថា បងស្រីរបស់គាត់ឈ្មោះ ទុយ វ៉ាត អាយុ ១៨ឆ្នាំ បានស្លាប់ដោយសារអត់អាហារបរិភោគនៅឆ្នាំ ១៩៧៦ និងម្តាមមីងរបស់គាត់ឈ្មោះ ពាន ត្រូវបានគេ ហៅអោយចុះពីផ្ទះហើយយកទៅបាត់ខ្លួនតែម្តង នៅឆ្នាំ ១៩៧៥។ ការស្លាប់របស់បងស្រីគាត់ និងការបាត់ខ្លួនរបស់ម្តាយមីងគាត់នេះ គឺជាការរងព្យសនកម្មដែលបានប្រព្រឹត្តតាមផែនការសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តទូទាំងប្រទេស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាគោលនយោបាយ នៃការធ្វើ ប្រតិបត្តិការមន្ទីសន្តិសុខ សហករណ៍ ឬការដ្ឋាន និងគោលនយោបាយ នៃការ អប់រំកែប្រែ សមាសភាពអាក្រក់ និងការសម្លាប់ ខ្មាំង ជាលទ្ធផលគឺស្លាប់ដោយការអត់អាហារ និងការបាត់ខ្លួននេះ។ | ទី ស្រីនណា, វ៉ែន ពៅ |
| 12-VSS-00484 | អ៊ូ សន | 3 | ដើបបណ្តឹងបានបញ្ជាក់ច្បាស់ហើយថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ គាត់បានបាត់បង់សាច់ញាតិរបស់គាត់ចំនួន ១០នាក់ រួមមាន ឪពុក ម្តាយ បងប្អូន និងកូន ព្យសនកម្មនេះដែលបានប្រព្រឹត្តតាមផែនការសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគោលនយោបាយ នៃការធ្វើប្រតិបត្តិការមន្ទីរសន្តិសុខ សហករណ៍ ឬការដ្ឋាន និងគោលនយោបាយ នៃការអប់រំកែប្រែ សមាសភាពអាក្រក់ និងការសម្លាប់ ខ្មាំង ជាលទ្ធផលគឺស្លាប់ដោយអត់អាហារ និងការបាត់ខ្លួននេះ។ | ទី ស្រីនណា, វ៉ែន ពៅ |

| ឯកសារយោង អង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 12-VSS-00498 | ពិន ហី | 5 | ដើមបណ្តឹងបានបញ្ជាក់យ៉ាងច្បាស់ថា នៅឆ្នាំ ១៩៧៥ កម្មាភិបាលខ្មែរក្រហមបានស្រាវជ្រាវរកពួកអ្នកធ្វើការរដ្ឋការដែលមានបណ្តាស័ក្តិរឿងនេះបានដឹងដល់មេភូមិ និងមេកងឈ្លបពីរឿងប្តីរបស់គាត់ធ្លាប់ធ្វើទាហានជំនាន់សង្គមរាស្ត្រនិយម គេក៏ហៅប្តីរបស់គាត់ថាអោយទៅរៀនសូត្រ ហើយបាត់ខ្លួនគាត់រហូត ព្យសនកម្មនេះដែលជាលទ្ធផល នៃការកំណត់គោលដៅលើក្រុមជាក់លាក់ គឺការកំណត់គោលដៅលើ អ្នករដ្ឋការសម័យសាធារណៈរដ្ឋខ្មែរ/ លន់ នល់។ | ទី ស្រីនណា, វ៉ែន ពៅ |
| 12-VSS-00547 | ឌុច ថេន | 6 | ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅឆ្នាំ១៩៧៧ ប្តីរបស់គាត់ឈ្មោះ មួន មេត ត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់ចោលដោយចោទថាជាពួកខ្សែ ការហ្សេបេ (KGB) ព្យសនកម្មនេះដែលជាលទ្ធផល នៃការកំណត់គោលដៅលើក្រុមជាក់លាក់ គឺការកំណត់គោលដៅលើ ចារកម្ម សេអ៊ីអា/កាហ្សេបេ (CIA/KGB) ។ | ទី ស្រីនណា, វ៉ែន ពៅ |
| 12-VSS-00560 | ស្វាយ ម៉ុន | 5 | ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅថ្ងៃទី ១៧ មេសា ១៩៧៥ បងស្រីបង្កើតរបស់គាត់ឈ្មោះ កន ប៊ូ និងគ្រួសារ ត្រូវបានពួកខ្មែរក្រហមជម្លៀសចេញពីភ្នំពេញ ទៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ នេះគឺជាព្យសនកម្ម ជាលទ្ធផល នៃការកំណត់គោលដៅលើក្រុមជាក់លាក់ គឺជាការកំណត់គោលដៅលើប្រជាជនថ្មី/ប្រជាជន១៧មេសា។ | ទី ស្រីនណា, វ៉ែន ពៅ |
| 12-VSS-00577 | តែម វត | 6 | ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា បងប្រុសរបស់គាត់ឈ្មោះ តែម សារុទ្ធ ត្រូវកម្មាភិបាលខ្មែរក្រហម យកទៅសម្លាប់នៅភ្នំប្រុសភ្នំស្រី ព្យសនកម្មនេះ ជាលទ្ធផលនៃការកំណត់គោលដៅលើក្រុមជាក់លាក់ គឺការកំណត់គោលដៅលើប្រជាជននៅភូមិភាគបូព៌ា។ | ទី ស្រីនណា, វ៉ែន ពៅ |

| ឯកសារយោងអង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 12-VSS-00582 | ឈុន សាម៉ន | 9 | ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅឆ្នាំ១៩៧៦ បងប្រុសរបស់គាត់ ត្រូវពួកខ្មែរក្រហមបង្ខំឲ្យចូលធ្វើជាទាហានខ្មែរក្រហមនៅស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង លុះដល់ឆ្នាំ១៩៧៧ បងប្រុសរបស់គាត់ ត្រូវពួកខ្មែរក្រហមបញ្ជូនឲ្យទៅបញ្ឈរជើងនៅប៉ៃលិន ពេលទៅដល់ទីនោះ ពួកខ្មែរក្រហមយកគាត់ទៅសម្លាប់ចោលដោយមិនដឹងមូលហេតុ ព្យសនកម្មនេះ ជាលទ្ធផលនៃការកំណត់គោលដៅលើក្រុមជាក់លាក់ គឺការកំណត់គោលដៅលើកម្មាភិបាលបក្សគុម្មុយនីយកម្ពុជា។ | ទី ស្រីនណា, វ៉ែន ពៅ |
| 12-VSS-00583 | ម៉ៅ វ៉ា | 5 | ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា បងប្រុសរបស់គាត់ឈ្មោះ ម៉ៅ ឆាន់ ជាទាហាន ត្រូវពួកខ្មែរក្រហមចាប់យកទៅបាត់រហូតដល់សព្វថ្ងៃ ព្យសនកម្មនេះ ដែលបានប្រព្រឹត្តតាមផែនការសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តទូទាំងប្រទេស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគោលនយោបាយ នៃការធ្វើប្រតិបត្តិការ មន្ទីរសន្តិសុខ សហករណ៍ ឬ ការដ្ឋាន និងគោលនយោបាយនៃការអប់រំកែប្រែ សមាសភាពអាក្រក់ និងការសម្លាប់ខ្មាំង។ | ទី ស្រីនណា, វ៉ែន ពៅ |
| 12-VSS-00624 | ដោក សុខគីន | 3 | ដើបបណ្តឹងបានបញ្ជាក់ច្បាស់ហើយថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ គាត់បានបាត់បង់សាច់ញាតិរបស់គាត់ គបងប្រុសពីរនាក់ និងបងថ្លៃស្រីម្នាក់ ព្យសនកម្មនេះដែលបានប្រព្រឹត្តតាមផែនការសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគោលនយោបាយ នៃការធ្វើប្រតិបត្តិការមន្ទីរសន្តិសុខ សហករណ៍ ឬការដ្ឋាន និងគោលនយោបាយ នៃការអប់រំកែប្រែ សមាសភាពអាក្រក់ និងការសម្លាប់ ខ្មាំង ជាលទ្ធផលគឺស្លាប់ដោយអត់អាហារ និងការបាត់ខ្លួននេះ។ | ទី ស្រីនណា, វ៉ែន ពៅ |

| ឯកសារយោងអង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 12-VSS-00672 | ញឹម កុល | 9 | យោងតាមពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D5/6767 គាត់បានបាត់បង់បងប្រុសពីរនាក់ ពូ មីង និងក្មួយចំនួន៤នាក់។ គាត់គ្រាន់តែជាអតីតកម្មាភិបាលខ្មែរក្រហមតូចតាចម្នាក់។ គ្មានវិធាន ឬយុទ្ធសាស្ត្រណាដែលហាមឃាត់អតីតកម្មាភិបាលខ្មែរក្រហម មិនអាចក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីដែរ។ ជាក់ស្តែងកាលក្នុងសំណុំរឿង ០០២ អតីតកម្មាភិបាល និងទាហានខ្មែរក្រហមមួយចំនួនត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ដូចជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសំគាល់ E3/4950 ជាដើម។ | ជេត វណ្ណលី |
| 12-VSS-00801 | ឡុង យន | 3 | យោងតាមពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D5/801 គាត់គួរតែត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រមខណ្ឌនៃសហឧក្រិដ្ឋកម្មរួម ដោយគាត់គឺជាជនរងគ្រោះដោយផ្ទាល់នៃការដាក់ឱ្យក្លាយជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត ការបង្ខំឱ្យធ្វើការ រស់នៅ និងហូបចុកនៅសហករណ៍ត្រាំកក់ និងជាជនរងគ្រោះមិនផ្ទាល់នៃការរៀបការដោយបង្ខំរបស់ប្អូនស្រីរបស់គាត់។ | ជេត វណ្ណលី |
| 12-VSS-00805 | ផាត់ ហន | 3 | យោងតាមពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D5/805 គាត់គួរតែត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រមខណ្ឌនៃសហឧក្រិដ្ឋកម្មរួម ដោយគាត់គឺជាជនរងគ្រោះដោយផ្ទាល់នៃការដាក់ឱ្យក្លាយជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត ។ បន្ថែមពីនេះគាត់គឺជាជនរងគ្រោះនៃការកំណត់គោលដៅជាប្រជាជនថ្មី ១៧មេសានិងជាជនរងគ្រោះមិនផ្ទាល់នៃការកំណត់គោលដៅលើអ្នករដ្ឋការសម័យលន់ នល់។ | ជេត វណ្ណលី |

| ឯកសារយោងអង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 12-VSS-00806 | ហង់ សុខ | 3 | យោងតាមពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D5/806 គាត់គួរតែត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុមខណ្ឌនៃសហឧក្រិដ្ឋកម្មរួម ដោយគាត់គឺជាជនរងគ្រោះដោយផ្ទាល់នៃការដាក់ឱ្យក្លាយជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត ការបង្ខំឱ្យធ្វើការ រស់នៅ និងហូបចុកនៅសហករណ៍ត្រាំកក់ ការរៀបការដោយបង្ខំនៅចុងឆ្នាំ១៩៧៦ និងការអប់រំកែប្រែ "សមាសភាពអាក្រក់" ដោយសារការដើរហើរដោយគ្មានការអនុញ្ញាត។ | ជេត វណ្ណលី |
| 12-VSS-00842 | ផន រឿន | 3 | យោងតាមពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D5/839 គាត់គួរតែត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុមខណ្ឌនៃសហឧក្រិដ្ឋកម្មរួម ដោយគាត់គឺជាជនរងគ្រោះដោយផ្ទាល់នៃការដាក់ឱ្យក្លាយជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត ការបង្ខំឱ្យធ្វើការ រស់នៅ និងហូបចុកនៅសហករណ៍ក្នុងអំឡុងឆ្នាំ១៩៧៦ ដល់១៩៧៩។ | ជេត វណ្ណលី |
| 13-VSS-00026 | វិញ សាម៉ិញ | 3, 6 | យោងតាមពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D5/864 អ្នកដាក់ពាក្យសុំគឺជាជនរងគ្រោះផ្ទាល់នៃការដាក់ឱ្យក្លាយជាទាសករនៅការដ្ឋានទំនប់ត្រពាំងថ្មនៅអំឡុងឆ្នាំ១៩៧៦។ គាត់គួរតែត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងក្រុមខណ្ឌនៃសហឧក្រិដ្ឋកម្មរួម។ | ជេត វណ្ណលី |

| ឯកសារយោងអង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 13-VSS-00073 | ជិន សាវ៉ៃ | 3 | ចៅក្រមមិនគួរផ្តោតទៅលើថ្ងៃខែឆ្នាំកំណើតដែលមាននៅក្នុងអត្តសញ្ញាណប័ណ្ណពេកនោះទេ តែគួរតែផ្តោតទៅលើហេតុការជាក់ស្តែងដែលជនរងគ្រោះបានទទួលរង ដោយសារមានករណីជាច្រើនដែលឯកសារអត្តសញ្ញាណប័ណ្ណមានកំហុសក្នុងការបំពេញដោយអាជ្ញាធរ។ ជាក់ស្តែងអ្នកដាក់ពាក្យសុំបានបញ្ជាក់ថា គាត់កើតនៅឆ្នាំ១៩៦១ មិនមែននៅឆ្នាំ១៩៧៤ ទេ ប៉ុន្តែដោយសារនីតិវិធីក្នុងការកែតម្រូវអត្តសញ្ញាណប័ណ្ណមានភាពស្មុគស្មាញ និងចំណាយពេលយូរ ទើបមិនអាចមានឯកសារដើម្បីភ្ជាប់ជូនតុលាការជ្រាប។ | ជេត វណ្ណលី |
| 13-VSS-00429 | ស្តើង មាច | 3 | យោងតាមពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D5/1267 ទោះប្បីគាត់ពុំបានចងចាំពេលវេលា និងទីកន្លែងច្បាស់លាស់អំពីការសម្លាប់សាច់ញាតិរបស់គាត់ក្តី ក៏គាត់គួរតែត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រមខណ្ឌនៃសហឧក្រិដ្ឋកម្មរួម ដោយគាត់គឺជាជនរងគ្រោះដោយផ្ទាល់នៃការដាក់ឱ្យក្លាយជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត។ | ជេត វណ្ណលី |

| ឯកសារយោងអង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 13-VSS-00743 | ចាន់ អ៊ុជ | 5, 7 | ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា នៅឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់បងស្រីគាត់ឈ្មោះ ចាន់ យុន ប្តីឈ្មោះ សាញ់ ម៉ឹក និងកូនៗ ចំនួន៥នាក់ទៀត ត្រូវបានជម្លៀសទៅស្រុកបាកាន និងស្រុកកណ្តៀងខេត្តពោធិសាត់ ដោយបំបែកក្រុមគ្រួសាររបស់គាត់ទៅតាមផ្នែករៀងៗខ្លួន និងបង្ខំឲ្យធ្វើការជាទម្ងន់។ ក្រោយមកបងថ្លៃរបស់គាត់ឈ្មោះ សាញ់ ម៉ឹក ជាអតីតទាហានយាមវាំង ត្រូវបានគេសម្លាប់នៅទួលពោធិជ្រៃ ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិសាត់។ ហើយក្រោយមកទៀត បងស្រីបង្កើត និងក្មួយៗចំនួន៤នាក់ទៀត់ក៏ត្រូវគេយកទៅសម្លាប់ចោលដែរ។  ព្យសនកម្មទាំងអស់នេះ ជាលទ្ធផលនៃការកំណត់គោលដៅលើក្រុមជាក់លាក់ គឺការកំណត់គោលដៅ លើអ្នករដ្ឋការសម័យសាធារណរដ្ឋខ្មែរ/លន់ ណុល និងការប្រព្រឹត្តតាមផែនការសហឧក្រិដ្ឋកម្មរួមដែលបានអនុវត្តទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគោលនយោបាយនៃការធ្វើប្រតិបត្តិការ មន្ទីរសន្តិសុខ សហករណ៍ ឬការដ្ឋាន។ | វ៉ែន ពៅ |

| ឯកសារយោងអង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 14-VSS-00185 | សឿង រ៉ា | 3 | ដើមបណ្តឹងបានបញ្ជាក់ច្បាស់ហើយថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ នៅឆ្នាំ ១៩៧៥ ពួកខ្មែរក្រហមបានជំលៀសគាត់ និងគ្រួសាររបស់គាត់ចេញពីទីក្រុងភ្នំពេញ នេះគឺជាព្យសនកម្មជាលទ្ធផលនៃការកំណត់គោលដៅលើក្រុមជាក់លាក់ គឺការកំណត់គោលដៅលើប្រជាជនថ្មី/ប្រជាជន១៧មេសា ហើយគាត់បានបាត់បង់សាច់ញាតិរបស់គាត់ គឺឪពុក ម្តាយ និងប្អូនប្រុសរបស់គាត់ ព្យសនកម្មនេះដែលបានប្រព្រឹត្តតាមផែនការសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគោលនយោបាយ នៃការធ្វើប្រតិបត្តិការមន្ទីរសន្តិសុខ សហករណ៍ ឬការដ្ឋាន និងគោលនយោបាយ នៃការអប់រំកែប្រែ សមាសភាពអាក្រក់ និងការសម្លាប់ ខ្មាំង ជាលទ្ធផលគឺស្លាប់ដោយអត់អាហារ និងការបាត់ខ្លួននេះ។ | ទី ស្រីនណា, វ៉ែន ពៅ |
| 15-VSS-00014 | កើត ធីតា | 7 | ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ពេលប៉ុលពតចូលមកនៅឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានជម្លៀសគ្រួសាររបស់គាត់ដោយបង្ខំចេញពីទីរួមខេត្តស្វាយរៀង ទៅស្រុករមាសហែកខេត្តស្វាយរៀង ហើយបានបំបែកគាត់ឲ្យទៅធ្វើការនៅអង្គភាព យុវណ្ណនារី ព្យសនកម្មនេះ ជាលទ្ធផលនៃការកំណត់គោលដៅក្រុមជាក់លាក់ គឺការកំណត់គោលដៅលើប្រជាជនថ្មី/ប្រជាជន១៧មេសា។ ហើយការបំបែកគាត់ឲ្យទៅធ្វើការជាទម្ងន់ នៅអង្គភាពយុវណ្ណនារី នោះ ព្យសនកម្មនេះ ដែលបានប្រព្រឹត្តតាមផែនការសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគោលនយោបាយនៃការធ្វើប្រតិបត្តិការ មន្ទីរសន្តិសុខ សហករណ៍ ឬការដ្ឋាន។ | ទី ស្រីនណា, វ៉ែន ពៅ |

| ឯកសារយោងអង្គភាពគាំពារជនរងគ្រោះ | ឈ្មោះ | មូលដ្ឋាននានាសម្រាប់ការបដិសេធ | ដាក់សំណើដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីកម្ពុជា |
|---|---|---|---|---|
| 15-VSS-00018 | ស្វូត្រ ហាន | 3 | ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបញ្ជាក់ថា នៅឆ្នាំ១៩៧៦ បងប្រុសរបស់គាត់ ធ្វើជាកងចល័តនៅបូព៌ា ហើយបានបញ្ជូនទៅវ៉ាយជាមួយនយួន នេះជាព្យសនកម្មជាលទ្ធផលនៃការកំណត់គោលដៅលើក្រុមជាក់លាក់ គឺការកណត់គោលដៅលើប្រជាជននៅភូមិភាគបូព៌ា។ | ទី ស្រីនណា, វ៉ែន ពៅ |
| 15-VSS-00056 | សាំង វ៉ាត់ | 3 | ដើបបណ្តឹងបានបញ្ជាក់ច្បាស់ហើយថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ពួកខ្មែរក្រហមបានជំលៀសគាត់ និងគ្រួសាររបស់គាត់ចេញពីខេត្ត តាកែវ មកខេត្ត កំពង់ស្ពឺ  នេះគឺជាព្យសនកម្មជាលទ្ធផលនៃការកំណត់គោលដៅលើក្រុមជាក់លាក់ គឺការកំណត់គោលដៅលើប្រជាជនថ្មី/ប្រជាជន១៧មេសា ហើយគាត់បានបាត់បង់ប្តីរបស់គាត់ ព្យសនកម្មនេះដែលបានប្រព្រឹត្តតាមផែនការសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគោលនយោបាយ នៃការធ្វើប្រតិបត្តិការមន្ទីរសន្តិសុខ សហករណ៍ ឬការដ្ឋាន។ | ទី ស្រីនណា, វ៉ែន ពៅ |